ក្រសួងមុខងារសាធារណៈ

# ប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម

ដោយឯកឧត្តម ឆាយ ឆត្រាវុធ

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤

# ប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម

## ១.សេចក្តីផ្តើម៖

- រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញនូវវិធានការគន្លឹះសំខាន់ៗទៅតាមវិស័យអាទិភាព ដើម្បីដោះស្រាយបញ្ហាប្រឈមនានា សំដៅធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងការឆ្លើយតបទាន់ពេលវេលាទៅនឹងគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាល។
- ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីរាជការ ការលើកកម្ពស់ប្រសិទ្ធភាពការងារ និងការរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈគឺជាការងារអាទិភាពដែលត្រូវរៀបចំ និងដាក់ឱ្យអនុវត្តដើម្បីពង្រឹងគុណភាពនិងសមត្ថភាពនៃរដ្ឋបាលសាធារណៈ រួមទាំងការរួមចំណែកក្នុងការលើកកម្ពស់គុណភាពនៃសេវាអប់រំ និងសុខាភិបាលនៅមូលដ្ឋាន។
- ក្នុងន័យនៃការគាំទ្រដល់ស្ថាប័ននិងមន្ត្រីដែលមានតួនាទីគន្លឹះ និងឆ្លើយតបទៅនឹងការងារអាទិភាព រាជរដ្ឋាភិបាលបានរៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មសម្រាប់អង្គភាព និងបុគ្គល ផ្អែកលើមូលដ្ឋាននៃការពិនិត្យនិងវាយតម្លៃគ្រប់ជ្រុងជ្រោយ ច្បាស់លាស់ និងតម្លាភាព ដើម្បីជំរុញការខិតខំប្រឹងប្រែងបំពេញតួនាទី និងភារកិច្ចឱ្យសម្រេចបាននូវលទ្ធផលកាន់តែប្រសើរ។

# ប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម

## ២.គោលបំណង៖

- ជម្រុញនិងលើកកម្ពស់ប្រសិទ្ធភាព និងសមិទ្ធផលការងាររបស់មន្ត្រីនិងអង្គភាព
- លើកកម្ពស់ការចូលរួម និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៅតាមអង្គភាព
- លើកទឹកចិត្តដល់មន្ត្រីនិងអង្គភាពដែលខិតខំប្រឹងប្រែងបំពេញការងារ និងមានស្នាដៃឆ្នើម
- ជម្រុញការកសាងភាពជាគំរូក្នុងការផ្តល់សេវាសាធារណៈរបស់មន្ត្រីនិងអង្គភាព។

# ប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម

**៣.វិសាលភាព៖**

- អង្គភាពដែលមានមុខងារគន្លឹះក្នុងក្របខណ្ឌដឹកនាំនិងគ្រប់គ្រងកម្រិតអគ្គនាយកដ្ឋាននៃក្រសួង ស្ថាប័ន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារអង្គភាពនិងមន្ត្រី
- អង្គភាពនិងមន្ត្រីដែលមានមុខងារគន្លឹះក្នុងផ្នែកគោលនយោបាយ នីតិកម្ម ធនធានមនុស្ស ថវិកា ត្រួតពិនិត្យ និងវាយតម្លៃ សិក្សានិងស្រាវជ្រាវក្នុងវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន
- អង្គភាពនិងមន្ត្រីដែលមានតួនាទីនិងភារកិច្ចក្នុងការរៀបចំនិងអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ វិស័យអប់រំ និងសុខាភិបាលរបស់រាជរដ្ឋាភិបាល និងការដ្ឋានកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល រួមមានការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ ការដ្ឋានកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងការដ្ឋានកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

# ប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម

៣.វិសាលភាព៖

- គ្រឹះស្ថានសិក្សានៅមូលដ្ឋាន រួមមានសាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃគ្រឹះស្ថានសិក្សា
- អង្គភាពសុខាភិបាលមូលដ្ឋាន រួមមានមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត ១ និងមន្ទីរពេទ្យបង្អែកកម្រិត ២ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃអង្គភាព។

# ប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម

**៤.លក្ខណៈវិនិច្ឆ័យ៖**

- ការពង្រឹងប្រព័ន្ធគ្រប់គ្រងវត្តមាន របៀបរបបបំពេញការងារ និងសមិទ្ធកម្មរបស់មន្ត្រីក្នុងអង្គភាព
- ការរៀបចំនិងដាក់ឱ្យអនុវត្តនិយាមនីតិវិធីស្តីពីប្រតិបត្តិការងាររបស់អង្គភាព
- ការរៀបចំនិងដាក់ឱ្យអនុវត្តផែនការសកម្មភាព (ប្រតិបត្តិការ)ប្រចាំឆ្នាំរបស់អង្គភាព
- ការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានក្នុងអង្គភាព
- ការរៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃវឌ្ឍនភាពការងាររបស់អង្គភាព
- របាយការណ៍សមិទ្ធកម្មជាទៀងទាត់

# ប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម

**៥.ការវាយតម្លៃ និងការកំណត់កម្រិតនៃសមិទ្ធកម្មអង្គភាព៖**

- សមិទ្ធកម្មកម្រិត១៖ អង្គភាពដែលបានបំពេញលក្ខណៈវិនិច្ឆ័យចាប់ពី ៩០% ឡើង
- សមិទ្ធកម្មកម្រិត២៖ អង្គភាពដែលបានបំពេញលក្ខណៈវិនិច្ឆ័យចាប់ពី ៨១% ដល់ ៨៩%
- សមិទ្ធកម្មកម្រិត៣៖ អង្គភាពដែលបានបំពេញលក្ខណៈវិនិច្ឆ័យចាប់ពី ៧១% ដល់ ៧៩%
- សមិទ្ធកម្មកម្រិត៤៖ អង្គភាពដែលបានបំពេញលក្ខណៈវិនិច្ឆ័យចាប់ពី ៦១% ដល់ ៧០%
- សមិទ្ធកម្មកម្រិត៥៖ អង្គភាពដែលបានបំពេញលក្ខណៈវិនិច្ឆ័យចាប់ពី ៥១% ដល់ ៦០%

# ប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម

**៦.ដំណាក់កាលនៃការវាយតម្លៃសមិទ្ធកម្ម និងយន្តការស្ថាប័នទទួលបន្ទុកវាយតម្លៃសមិទ្ធកម្ម៖**

ដំណាក់កាលទី១៖ ការវាយតម្លៃសមិទ្ធកម្មអង្គភាពដោយគណៈកម្មការវាយតម្លៃសមិទ្ធកម្មរបស់ក្រសួង ស្ថាប័ន

ដំណាក់កាលទី២៖ គណៈកម្មការជាតិវាយតម្លៃសមិទ្ធកម្មអង្គភាព មានសមាសភាពពីក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងអធិការកិច្ច។ គណៈកម្មការជាតិទទួលបន្ទុកពិនិត្យផ្ទៀងផ្ទាត់ និងវាយតម្លៃជាលើកទី២លើសមិទ្ធកម្មរបស់អង្គភាពដែលត្រូវបានបញ្ជូនមកដោយគណៈកម្មការវាយតម្លៃសមិទ្ធកម្មរបស់ក្រសួង។

# ប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម

សេចក្តីសន្និដ្ឋាន

- អង្គភាពនិងមន្ត្រីដែលមានមុខងារកន្លឹះក្នុងផ្នែកគោលនយោបាយ នីតិកម្ម ធនធានមនុស្ស ថវិកា ត្រួតពិនិត្យ និងវាយតម្លៃ សិក្សានិងស្រាវជ្រាវក្នុងវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល និងក្រសួងស្ថាប័ន
- អង្គភាពនិងមន្ត្រីដែលមានតួនាទីភារកិច្ចក្នុងការរៀបចំនិងការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ វិស័យអប់រំ និងវិស័យសុខាភិបាល និងការដ្ឋានកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល រួមមានការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ ការដ្ឋានកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ការដ្ឋានកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
- គ្រឹះស្ថានសិក្សានៅមូលដ្ឋាន៖ សាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីនៃគ្រឹះស្ថានសិក្សា
- អង្គភាពសុខាភិបាលមូលដ្ឋាន៖ មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ មន្ទីរពេទ្យបង្អែកកម្រិត២ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃអង្គភាព

# សូមអរគុណ